ក្រសួងបរិស្ថាន

# នាយកដ្ឋានប្រែប្រួលអាកាសធាតុ

ព្រឹត្តិបត្រព័ត៌មាន លេខ២ ខែមករា ឆ្នាំ២០១៤

## ការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុរយៈពេល ១០ឆ្នាំ




*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ នៅក្នុងពិធីបើកវេទិកាជាតិលើកទី៣ ស្ដីពីការប្រែប្រួលអាកាសធាតុ នៅខែវិច្ឆិកា ឆ្នាំ២០១៣*

ថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ២០១៣ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ (ផ.យ.ប.អ.ក.) ដំបូងបង្អស់ នៅក្នុងវេទិកាជាតិលើកទី៣ ស្ដីពីការប្រែប្រួលអាកាសធាតុ។

ផ.យ.ប.អ.ក. ផ្ដោតលើទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ដើម្បីលើកស្ទួយការអភិវឌ្ឍដោយចីរភាព ដែលយើងត្រូវប្រកាន់យកក្នុងរយៈពេល ១០ឆ្នាំខាងមុខ។ ឯកសារយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំដោយផ្អែកលើគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលមានស្រាប់ ដើម្បីធានាឱ្យបាននូវក្របខ័ណ្ឌយុទ្ធសាស្ត្រប្រទាក់ក្រឡាគ្នាសម្រាប់ដោះស្រាយបញ្ហាជាច្រើននៃការប្រែប្រួលអាកាសធាតុ តាមរយៈវិធានការបន្សាំ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍដោយបញ្ចេញកាបូនតិច។

ឯកសារយុទ្ធសាស្ត្រនេះ ក៏បានកំណត់ផងដែរនូវវិធានការជាច្រើន ដែលសង្កត់ធ្ងន់លើការកសាងសមត្ថភាពស្ថាប័ន និងចំណេះដឹងវិទ្យាសាស្ត្រសម្រាប់ប៉ាន់ប្រមាណផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការបន្សាំ និងការកាត់បន្ថយគ្រោះមហន្តរាយ ជាពិសេសសម្រាប់វិស័យងាយរងគ្រោះដូចជា កសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ ព្រៃឈើ ជលផល និងទេសចរណ៍ ជាដើម។ ផែនការយុទ្ធសាស្ត្រនេះក៏បានគិតគូរផងដែរ អំពីការកសាងសមត្ថភាពធន់ទ្រាំ និងជំនាញផលិតកម្ម ជាពិសេស

តទៅទំព័រទី២

**ផ.យ.ប.អ.ក. មានទិសដៅជាយុទ្ធសាស្ត្រចំនួន ៨ ៖**

១. លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល។

២. កាត់បន្ថយភាពងាយរងគ្រោះនៃវិស័យ តំបន់ យេនឌ័រ និងសុខភាពនៅចំពោះមុខការប្រែប្រួលអាកាសធាតុ។

៣. លើកកម្ពស់ភាពធន់នឹងអាកាសធាតុ នៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌។

៤. លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។

៥. ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹង សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

៦. លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គម តាមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត។

៧. ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។

៨. ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់តំបន់ និងពិភពលោក។

## មាតិកា


| | |
|---|---|
| ការប្រកាសដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ ១0ឆ្នាំ | 1 |
| គម្រោងបន្សាំរួមចំណែកដល់ការត្រៀមលក្ខណៈ និងឆ្លើយតបទឹកជំនន់ | 1-3 |
| ការប្រែក្លាយការអនុវត្តសាកល្បង ទៅជា ការបង្កើតប្រព័ន្ធជាតិសម្រាប់ពង្រឹងការឆ្លើយតប | 4 |
| ក្របខ័ណ្ឌជាតិសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃ ចាប់ផ្ដើមនៅកម្ពុជា | 4 |
| ជំហររបស់កម្ពុជានៅក្នុង CoP 19 | 5 |
| ព័ត៌មានសំខាន់ | 6 |


## គម្រោងបន្សាំរួមចំណែកដល់ការត្រៀមលក្ខណៈ និងឆ្លើយតបទឹកជំនន់

គម្រោងសាកល្បងការប្រែប្រួលអាកាសធាតុ ដែលទទួលមូលនិធិពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ត្រូវបានបង្កើតឡើង ដើម្បីបង្កើនភាពធន់របស់សហគមន៍ដែលងាយរងគ្រោះនឹងផលប៉ះពាល់រយៈពេលវែង នៃការប្រែប្រួលអាកាសធាតុ។ គម្រោងទាំងនេះ ក៏នាំមកនូវអត្ថប្រយោជន៍ចំពោះមុខសម្រាប់ប្រជាជននៅមូលដ្ឋាន ដែលព្យាយាមបន្សាំទៅនឹងវិសម្ភាពអាកាសធាតុបច្ចុប្បន្ន និងព្រឹត្តិការណ៍មិនប្រក្រតី។

គម្រោងបន្សាំនៅមូលដ្ឋាន បានជួយកាត់បន្ថយភាពងាយរងគ្រោះក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងពេលទទួលរងគ្រោះទឹកជំនន់ ចន្លោះខែសីហា និងតុលា ឆ្នាំ២០១៣ ដែលបានបង្កផលប៉ះពាល់ ដល់ខេត្តចំនួន ២១ ប្រជាពលរដ្ឋជាង ៤០០.០០០ គ្រួសារ និងនាំឱ្យបាត់បង់ជីវិតមនុស្សយ៉ាងតិច ១៦៨នាក់។

តទៅទំព័រទី២

## ការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការ.......

នៅថ្នាក់សហគមន៍ ដើម្បីជំនះលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ការអនុវត្តផែនការយុទ្ធសាស្ត្រទាមទារឱ្យមានអភិក្រមផ្តែកលើកម្មវិធី ដើម្បីធានានូវការសម្របសម្រួលជាយុទ្ធសាស្ត្រ និងការកំណត់នូវសកម្មភាពជាអាទិភាព។ សកម្មភាពទាំងនោះរួមមាន i) ការចាត់ចែងចេនាសម្ព័ន្ធស្ថាប័ននៅកម្រិតថ្នាក់ជាតិ ក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិ ii) ការកសាងផែនការសកម្មភាពពីសំណាក់ក្រសួងពាក់ព័ន្ធទាំងអស់ iii) ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ តាមរយៈការប្រើប្រាស់នូវគំរូផ្តល់មូលនិធិផ្សេងៗគ្នាមួយចំនួន iv) ការបង្កើតក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីវាស់វែងពីប្រសិទ្ធិភាពនៃវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងទទួលបានមេរៀនបទពិសោធន៍ និង v) ការបង្កើតក្របខ័ណ្ឌច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ តាមរយៈការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយពាក់ព័ន្ធ និងច្បាប់សំខាន់ៗ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹង
ការប្រែប្រួលអាកាសធាតុកម្ពុជា

២០១៤-២០២៣

ឆ្នាំ២០១៣
គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
ការសម្របសម្រួលវិធានការឆ្លើយតបទៅនឹងការប្រែប្រួល
តាមដានការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

វិស័យឯកជនអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ
ជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួល
ការប្រែប្រួលអាកាសធាតុ ជាពិសេសផែនការយុទ្ធសាស្ត្រនេះ
ដែលបៃតង បញ្ចេញកាបូនតិច ធន់ទ្រាំនឹងការប្រែប្រួល

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០១៣

ហ៊ុន សែន

# សកម្មភាពនៅមូលដ្ឋាន ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

## គម្រោងបន្សាំរួមចំណែកដល់ការត្រៀមលក្ខណៈ............

គម្រោងសាកល្បងជាច្រើនរបស់ CCCA បានរួមចំណែកបង្កើនការត្រៀមលក្ខណៈ និងភាពធន់របស់សហគមន៍ងាយរងគ្រោះ ដូចខាងក្រោម៖

### *ការបង្កើនភាពធន់នឹងអាកាសធាតុតាមរយៈប្រព័ន្ធស្រោចស្រព៖ ទំនប់ខ្លុបត្របែក ខេត្តតាកែវ*

ទំនប់ខ្លុបត្របែក ដែលមានសមត្ថភាពស្តុកទឹកជាង ៣៣លានម៉ែត្រគូប និងប្រព័ន្ធស្រោចស្រពពាក់ព័ន្ធផ្សេងទៀត បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ទឹកសម្រាប់ដំណាំស្រូវ និងការបង្កើនផលត្រីក្នុងស្រែ សម្រាប់ឃុំចំនួនប្រាំមួយ។ នៅពេលមានទឹកជំនន់ និងធ្លាក់ភ្លៀងខ្លាំងម្តងៗ ទំនប់នេះប្រឈមនឹងសម្ពាធទឹកខ្លាំងខុសពីធម្មតា ដែលអាចនឹងបាក់ ហើយបង្កហានិភ័យដល់អាយុជីវិត និងរបរចិញ្ចឹមជីវិតរបស់សហគមន៍ជិតខាង ប្រសិនបើគ្មានការគ្រប់គ្រងឱ្យបានសមស្រប។


*គណៈកម្មការថែទាំទំនប់ខ្លុបត្របែក បង្ហាញអំពីរបៀបនៃការឆ្លើយតបនឹងប្រែប្រួលអាកាសធាតុ*

តាមរយៈគម្រោង "កសាងប្រព័ន្ធផលិតកម្មស្បៀងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដោយការភ្ជាប់ប្រព័ន្ធចិញ្ចឹមត្រីក្នុងស្រែ ទៅនឹងទំនប់" ដែលអនុវត្តដោយសាលាជាតិកសិកម្មព្រែកលៀប CCCA បានផ្តល់ការគាំទ្រ ដូចខាងក្រោម៖

*១) អនុវត្តការងារចាំបាច់ដើម្បីជួសជុល និងថែទាំទំនប់ ក្នុងភាពជាដៃគូជាមួយមន្ទីរធនធានទឹកខេត្ត និង ២) កសាងសមត្ថភាពគណៈកម្មការគ្រប់គ្រងទឹកនៅមូលដ្ឋាន ដើម្បីគ្រប់គ្រងរំដោះទឹកចេញពីទំនប់នេះឱ្យមានប្រសិទ្ធភាព ដោយមានកិច្ចសហការជាមួយគណៈកម្មការទំនប់ទឹកខាងលើ នៅពេលមានហានិភ័យខ្លាំង។*

ការរួមបញ្ចូលការថែទាំ និងការអភិវឌ្ឍសមត្ថភាពប្រកបដោយប្រសិទ្ធភាព សម្រាប់ការគ្រប់គ្រងទំនប់ទឹកនៅមូលដ្ឋាន បានធ្វើឱ្យឃុំពាក់ព័ន្ធទាំងប្រាំមួយ អាចគ្រប់គ្រងផលប៉ះពាល់ដោយទឹកជំនន់ឆ្នាំ២០១៣ យ៉ាងមានប្រសិទ្ធភាព និងបានការពារស្រែដំណាំជាង ១.០០០ ហិកតាផងដែរ។


*ការរួមបញ្ចូលប្រព័ន្ធចិញ្ចឹមត្រីនៅក្នុងស្រែ សម្រាប់ភាពធន់នឹងអាកាសធាតុ*

## ផ្លូវលំជនបទធន់នឹងទឹកជំនន់៖ ឃុំបូរីជលសារ ខេត្តតាកែវ

ដោយមានការគាំទ្រហិរញ្ញវត្ថុពី CCCA គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) បានផ្តល់ជំនួយបច្ចេកទេសដល់ឃុំសាកល្បងមួយចំនួន ក្នុងខេត្តតាកែវ ដើម្បីកែលម្អការកសាងផែនការ និងរៀបចំកម្មវិធីវិនិយោគ ក្នុងបរិបទប្រែប្រួលអាកាសធាតុ។ ហិរញ្ញប្បទានអាកាសធាតុក្នុងទម្រង់ជាមូលនិធិគម្រោងសាកល្បង ត្រូវបានផ្តល់តាមរយៈប្រព័ន្ធជាតិ ដើម្បីបំពេញបន្ថែមលើមូលនិធិឃុំ/សង្កាត់ និងការវិនិយោគសកម្មភាពអាទិភាពដែលមានភាពធន់នឹងអាកាសធាតុ។ នៅឃុំបូរីជលសារ ផ្លូវថ្នល់មួយខ្សែត្រូវបានសាងសង់ដោយគោរពតាមស្តង់ដារទាំងនេះ។ ផ្លូវថ្មីនេះ អាចធន់នឹងទឹកជំនន់ខែតុលា ឆ្នាំ២០១៣ និងអាចឱ្យប្រជាជន ៨៩២គ្រួសារ បន្តទទួលបាននូវសេវា និងទីផ្សារលក់ផលិតផលរបស់ខ្លួននៅពេលមានទឹកជំនន់ មិនដូចផ្លូវថ្នល់នៅជិតនោះដែលសាងសង់ "តាមទម្លាប់ធម្មតា"។ នេះគឺជាឧទាហរណ៍មួយអំពីការទទួលផលត្រឡប់ពីការវិនិយោគ និងប្រសិទ្ធិភាពខ្ពស់នៃការចំណាយលើហេដ្ឋារចនាសម្ព័ន្ធ ដែលធន់នឹងអាកាសធាតុ។



*ផ្លូវថ្នល់ធន់នឹងអាកាសធាតុ នៅឃុំបូរីជលសារ ខេត្តតាកែវ*

## ការរួមបញ្ចូលការត្រៀមបង្ការទប់ទល់នឹងអាកាសធាតុ និងគ្រោះមហន្តរាយ៖ ស្រុកឯកភ្នំ ខេត្តបាត់ដំបង

ស្រុកឯកភ្នំ ស្ថិតនៅភាគខាងលិចនៃបឹងទន្លេសាប និងជិតស្ទឹងសង្កែ គឺជាស្រុកដែលងាយរងគ្រោះ ជាពិសេសដោយទឹកជំនន់ ហើយជាក់ស្តែងធ្លាប់បានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់ឆ្នាំ២០១៣។

គម្រោងសាកល្បងនេះ មានគំនិតច្នៃប្រឌិតថ្មី ដោយផ្តែកលើភាពជាដៃគូដ៏រឹងមាំជាមួយសមាគមមនុស្សចាស់ក្នុងឃុំពាក់ព័ន្ធ តាមរយៈការផ្តល់សេវា និងការគ្រប់គ្រងធនធាននានាសម្រាប់សកម្មភាពបន្សាំនឹងអាកាសធាតុ ដូចជា ការចែកធុងចម្រោះទឹក និងពាងផែនដី សម្រាប់ផ្តល់ទឹកស្អាតនៅពេលមានទឹកជំនន់។



*ការទទួលបានទឹកស្អាត តាមរយៈពាងផែនដី នៅភូមិបាក់អម្រែក ស្រុកឯកភ្នំ ខេត្តបាត់ដំបង*

លោក ***ហួម កុសល*** សមាជិកក្រុមប្រឹក្សាឃុំព្រែកហ្លួង បានកត់សំគាល់ថា បញ្ហាសុខភាពនៅឃុំរបស់គាត់នាពេលមានទឹកជំនន់ឆ្នាំ២០១៣ ត្រូវបានកាត់បន្ថយ បើធៀបនឹងឆ្នាំមុនៗ។ ពូជស្រូវស្រាល (ជលសារ សែនពិដោរ និងអ៊ីអ៊ែរ៦៦) ដែលអាចប្រមូលផលនៅមុនពេលមានទឹកជំនន់មកដល់ ក៏ត្រូវបានណែនាំឱ្យប្រើប្រាស់ ដូច្នេះអាចបញ្ចៀសផលប៉ះពាល់ធ្ងន់ធ្ងរចំពោះដំណាំស្រូវរបស់កសិករ។

### វិធានការបន្សាំដទៃទៀត ដែលអ្នកភូមិទទួលបាន រួមមាន៖

១. រៀបចំសួនបន្លែនៅទីទួល និងដាំបន្លែក្នុងកន្ត្រកឬពេលមានទឹកជំនន់។

២. ទទួលបានជំនាញមួយចំនួន ពីវគ្គបណ្តុះបណ្តាលស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក៏ត្រូវបានយកមកអនុវត្ត រួមមាន ការតាមដានព័ត៌មានព្យាករណ៍ធាតុអាកាសដែលប្រសើរជាងមុនតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋាភិបាល និងឯកជន វិធានការទប់ស្កាត់សត្វពស់ និងសត្វល្អិតខាំនៅពេលមានទឹកជំនន់ និងការចែកចាយឧបករណ៍កាត់បន្ថយគ្រោះមហន្តរាយនៅពេលមានទឹកជំនន់ ដល់គ្រួសារដែលងាយរងគ្រោះ និងបានរងគ្រោះធ្ងន់ធ្ងរជាងគេ។

៣. វិធានការបន្សាំមួយចំនួនទៀត ត្រូវបានស្នើឡើងដើម្បីបញ្ចូលទៅក្នុងកម្មវិធីវិនិយោគឃុំ ឆ្នាំ២០១៤ ដោយផ្អែកលើបទពិសោធន៍ទទួលបាននៅឆ្នាំ២០១៣។ វិធានការទាំងនោះរួមមាន ការស្តារ និងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៃផ្លូវថ្នល់ និងទ្វារបិទ-បើកទឹក ការដាំស្រូវ និងបន្លែ និងដើមឈើដែលធន់នឹងអាកាសធាតុ។

## ការប្រែក្លាយការអនុវត្តសាកល្បង ទៅជា ការបង្កើតប្រព័ន្ធជាតិសម្រាប់ពង្រឹងការឆ្លើយតប

កម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅមុខដោយរលូន ឈានទៅរកការសម្រេចបាននូវចក្ខុវិស័យក្នុងការបង្កើតប្រព័ន្ធជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ បានកត់សំគាល់នៅក្នុងសុន្ទរកថានៃវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ថា *"ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទឹកប្រាក់ប្រមាណ ២៥០លានដុល្លា ត្រូវបានកៀរគរ ដើម្បីគាំទ្រដល់ការអនុវត្តគម្រោងប្រែប្រួលអាកាសធាតុនានា។ (...) សកម្មភាពទាំងនេះ កំពុងផ្តល់មេរៀនជាច្រើនសម្រាប់គាំទ្រដល់ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ"*។

បទពិសោធន៍ដ៏សំបូរបែបដូចខាងក្រោម កំពុងត្រូវបានយកមកប្រើប្រាស់ ដើម្បីបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុឱ្យមានភាពស៊ីសង្វាក់ មានភាពទាក់ទាញ និងអាចទុកចិត្តបានសម្រាប់កម្ពុជា ៖

- ផ្អែកលើផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក្រសួង/ស្ថាប័នពាក់ព័ន្ធកំពុងរៀបចំសេចក្តីព្រាងបញ្ចប់នៃផែនការសកម្មភាពប្រែប្រួលអាកាសធាតុ។
- បែបបទគំរូផ្សេងៗគ្នាដែលមានស្រាប់សម្រាប់ការផ្តល់ហិរញ្ញប្បទានអាកាសធាតុ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ កំពុងស្ថិតក្នុងការពិនិត្យឡើងវិញ ជាមួយនឹងការដាក់បន្ថែមជម្រើសនានា (ដូចជា ការគាំទ្រថវិកា) ហើយជំហរដាក់លាក់របស់រាជរដ្ឋាភិបាលនឹងត្រូវបង្ហាញជូននៅដើមឆ្នាំ ២០១៤នេះ។
- ការវិភាគដំបូងលើថ្លៃចំណាយ និងផលចំណេញ នៃអន្តរាគមន៍ការប្រែប្រួលអាកាសធាតុ កំពុងត្រូវបានរៀបចំសិក្សា។




*ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្នុងពេលថ្លែងសុន្ទរកថា ក្នុងវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ*

- ការចាត់ចែងស្ថាប័ន និងក្របខ័ណ្ឌច្បាប់ស្តីពីប្រែប្រួលអាកាសធាតុកំពុងស្ថិតក្នុងការពិនិត្យឡើងវិញ។
- ក្របខ័ណ្ឌជាតិពិនិត្យតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុ កំពុងស្ថិតក្នុងការបង្កើត និងរួមបញ្ចូលជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការស្រាវជ្រាវដាក់លាក់ និងការវិភាគផលចំណេញពីការចំណាយលើការប្រែប្រួលអាកាសធាតុ នឹងក្លាយជាផ្នែកមួយនៃក្របខ័ណ្ឌនេះ។

## ក្របខ័ណ្ឌជាតិពិនិត្យតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុចាប់ផ្តើមនៅកម្ពុជា

នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន បានរៀបចំសិក្ខាសាលាស្តីពីការបង្កើត "**ក្របខ័ណ្ឌជាតិពិនិត្យតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុ**" នៅថ្ងៃទី ១២-១៣ ខែធ្នូ ឆ្នាំ២០១៣ នៅខេត្តព្រះសីហនុ។

សិក្ខាសាលានេះ មានគោលបំណងផ្តួចផ្តើមបង្កើតក្របខ័ណ្ឌជាតិពិនិត្យតាមដាន និងវាយតម្លៃ សម្រាប់តាមដាន ប្រសិទ្ធភាពនៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ និងដើម្បីចែករំលែកបទពិសោធន៍របស់បណ្តាប្រទេសនានា និងការអនុវត្តល្អៗ។ អ្នកចូលរួមប្រមាណ ៨០រូប អញ្ជើញមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗ អង្គការមិនមែនរដ្ឋាភិបាល និងគ្រឹះស្ថានសិក្សា។

ការបង្កើតក្របខ័ណ្ឌជាតិពិនិត្យតាមដាន និងវាយតម្លៃ គឺជាសកម្មភាពអាទិភាពមួយក្នុងចំណោមសកម្មភាពអាទិភាពនានា ដែលត្រូវបានកំណត់នៅក្នុង ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅខែវិច្ឆិកា ឆ្នាំ២០១៣។ ក្របខ័ណ្ឌនេះ មានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីពិនិត្យមើលការអនុវត្តយុទ្ធសាស្ត្រនេះ និងការវិនិយោគនានាបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយ និងការអភិវឌ្ឍដែលបញ្ចេញកាបូនតិច។

ព្រឹត្តិការណ៍នេះបានផ្តោតលើការចែករំលែកមេរៀន និងការអនុវត្តល្អៗពី




*ពិធីបើកសិក្ខាសាលាស្តីពីការបង្កើតក្របខ័ណ្ឌជាតិ M&E ប្រែប្រួលអាកាសធាតុ*

អន្តរជាតិ អំពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃ (M&E) សម្រាប់ការបន្សាំ ដោយផ្អែកលើគម្រោង "តាមដានការបន្សាំ និងវាស់ការអភិវឌ្ឍ (TAMD)" ដែលអនុវត្តដោយវិទ្យាស្ថានអន្តរជាតិសម្រាប់បរិស្ថាន និងការអភិវឌ្ឍ នៅក្នុងប្រទេសកំពុងអភិវឌ្ឍមួយចំនួន រួមទាំង កេនយ៉ា និងនេប៉ាល់។ ទម្រង់រួមនៃក្របខ័ណ្ឌជាតិ M&E សម្រាប់ការប្រែប្រួលអាកាសធាតុ ត្រូវបានធ្វើបទបង្ហាញដោយមន្ត្រីនាយកដ្ឋានប្រែប្រួលអាកាសធាតុ និងពិភាក្សាជាមួយអ្នកពាក់ព័ន្ធ សូចនាករនានាសម្រាប់ការប្រែប្រួលអាកាសធាតុ ត្រូវបានកំណត់

តទៅទំព័រទី៦

## កិច្ចប្រជុំកំពូលលើកទី១៩ នៃUNFCCC

កិច្ចប្រជុំកំពូលទី១៩ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (CoP 19 to UNFCCC) ត្រូវបានរៀបចំ ចាប់ពីថ្ងៃទី ១១-២២ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅទីក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ ដែលបានប្រព្រឹត្តទៅមួយសប្តាហ៍ក្រោយពីការរៀបចំវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ នៅកម្ពុជា។ ពិធីនេះមានការចូលរួមពីតំណាង ១៨៩ ប្រទេសភាគីជាសមាជិក រួមទាំង អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មាន សរុបប្រមាណ ១០.០០០នាក់។ សម្រាប់កម្ពុជា មានប្រតិភូចំនួន ១៦ រូប ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលក្នុងនោះមានប្រតិភូតំណាងក្រសួងបរិស្ថាន និងតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### គោលជំហរគន្លឹះរបស់កម្ពុជា រួមមាន៖

- គាំទ្រដល់កិច្ចប្រឹងប្រែង ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើគោលការណ៍ UNFCCC និងការភ្ជាប់ខ្លួនជាមួយប្រទេសអភិវឌ្ឍតិចតួច (LDCs) និង G77+ ចិន។
- តម្រូវឱ្យប្រទេសជឿនលឿន នាំមុខក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ចំណែក ប្រទេសកំពុងអភិវឌ្ឍ អាចចូលរួមដោយស្ម័គ្រចិត្ត ដោយផ្អែកលើការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកវិទ្យា។
- គាំទ្រដល់ផែនការបន្សាំជាតិនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងកម្មវិធីការងារស្តីពីការបាត់បង់ និងការខូចខាត ដោយផ្អែកលើអាទិភាពរបស់ប្រទេសនីមួយៗ។
- អំពាវនាវឱ្យមានការអនុវត្តក្របខ័ណ្ឌបន្សាំ ដែលត្រូវបានបង្កើតឡើងនៅកាន់គុន និងមាត្រានានាក្នុងក្របខ័ណ្ឌនេះ សម្រាប់ដំណើការរបស់ LDCs ដើម្បីឱ្យមានការបន្សាំនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។
- គាំទ្រដល់អំឡុងពេលនៃការប្តេជ្ញាលើកទីពីរក្រោមពិធីសារក្យូតូ។
- អំពាវនាវឱ្យមានការឯកភាពលើវិធីសាស្រ្ត និងគំរូសម្រាប់ការអនុវត្តការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ (REDD$^{+}$)។
- គាំទ្រដល់ការផ្តល់ហិរញ្ញវត្ថុដែលអាចព្យាករណ៍បាន បន្ថែម និងថ្មី ពីប្រភពសាធារណៈ ពីសំណាក់ប្រទេសអភិវឌ្ឍន៍។
- លើកទឹកចិត្តប្រទេសជឿនលឿន ឱ្យផ្តល់ការគាំទ្រថវិកា ១០០ពាន់លានដុល្លាអាមេរិកក្នុងមួយឆ្នាំ ដល់ប្រទេសកំពុងអភិវឌ្ឍន៍រហូតដល់ឆ្នាំ២០២០។ អំពាវនាវឱ្យមានផែនទីបង្ហាញផ្លូវហិរញ្ញវត្ថុពិស្តារ ដើម្បីផ្តល់ហិរញ្ញវត្ថុថ្មីអាចព្យាករណ៍បាន និងបន្ថែមពីប្រភពសាធារណៈដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបំពេញភាពខ្វះខាតរវាង ឆ្នាំ២០១៣-២០២០ ។
- គាំទ្រឱ្យមានការពង្រឹងសកម្មភាព ដើម្បីលើកកម្ពស់សមត្ថភាព និងលទ្ធភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ ការកសាងសមត្ថភាពគួរតែជាសកម្មភាពបន្ត នាំមុខដោយប្រទេសជាម្ចាស់ផ្ទះ មានបែបផែនជាការចូលរួមពេញលេញ និងដំណើរការចម្រុះ។

### បន្ទាប់ពី CoP 19:

**រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តជាគោលការណ៍ ឱ្យក្រសួងបរិស្ថានអនុវត្តសកម្មភាពដូចតទៅ៖**

- ពិនិត្យលទ្ធភាពផ្តល់សច្ចាប័នលើវិសោធនកម្មទីក្រុងដូហានៃពិធីសារក្យូតូ ដើម្បីអាចឱ្យកម្ពុជាបន្តចូលរួមអនុវត្តបណ្តាគម្រោងយន្តការអភិវឌ្ឍន៍ស្អាត នៅក្នុងដំណាក់កាលប្តេជ្ញាលើកទីពីរ នៃការអនុវត្តពិធីសារក្យូតូ នៅឆ្នាំ ២០១២-២០២០។
- ចាត់តាំងក្រសួងបរិស្ថានជាអង្គភាពថ្នាក់ជាតិសម្រាប់សម្របសម្រួលការងារ REDD$^{+}$ ហើយជូនដំណឹងជាផ្លូវការទៅលេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តិពីការប្រែប្រួលអាកាសធាតុ។
- អនុញ្ញាតជាគោលការណ៍ជូនក្រសួងបរិស្ថាន សហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីពិនិត្យសិក្សាសំណើរបស់ភាគីជប៉ុន ស្តីពីការអនុវត្តយន្តការឥណទានកាបូនរួមគ្នា (Joint Crediting Mechanism) មុននឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។




*អគ្គលេខាធិការ អ.ស.ប ថ្លែងអំពីការប្តេជ្ញាចិត្តដោះស្រាយការប្រែប្រួលអាកាសធាតុ នៅក្នុងCoP 19 ប្រទេសប៉ូឡូញ*




*រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានNCCC បានអំពាវនាវដល់សហគមន៍អន្តរជាតិឱ្យធ្វើការដោះស្រាយការប្រែប្រួលអាកាសធាតុ នៅក្នុងCoP 19 ប្រទេសប៉ូឡូញ*

### សេចក្តីសម្រេចចិត្តរបស់ CoP 19:

- បន្តរៀបចំកិច្ចព្រមព្រៀងផ្លូវច្បាប់ថ្មីមួយ សម្រាប់ដាក់ជូនសន្និសីទកំពូលលើកទី២១ អនុម័ត នាទីក្រុងប៉ារីស នៅចុងឆ្នាំ២០១៥ ហើយត្រូវចូលជាធរមានចាប់ពីឆ្នាំ២០២០ តទៅ។
- សម្រេចបង្កើតយន្តការអន្តរជាតិវ៉ាសូវី សម្រាប់ការបាត់បង់ និងការខូចខាតនៅក្រោមក្របខ័ណ្ឌបន្សាំកាន់គុន។
- បន្តខិតខំដោះស្រាយបញ្ហាកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ នៅមុនឆ្នាំ២០២០ តាមរយៈវិធានការបច្ចេកទេស និងជំរុញឱ្យមានការចូលរួមកាន់តែច្រើនថែមទៀតពីថ្នាក់រដ្ឋមន្ត្រី។
- ប្រទេសជឿនលឿនបានប្រកាសផ្តល់ថវិកាលើសពី ១០០ពាន់លានដុល្លាអាមេរិក សម្រាប់មូលនិធិបន្សាំក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយសហរដ្ឋអាមេរិក ន័រវែស និងចក្រភពអង់គ្លេស ក៏បានសន្យាផ្តល់ហិរញ្ញប្បទានចំនួន ២៨០លានដុល្លាអាមេរិក សម្រាប់ការងារ REDD$^{+}$។
- ក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុបៃតង នឹងចាប់ដំណើរការកៀរគរធនធានក្នុងពេលឆាប់ៗនេះ ដោយស្នើឱ្យប្រទេសអភិវឌ្ឍរួមចំណែកឱ្យបានខ្លាំងក្លា ក្នុងការផ្តល់ហិរញ្ញប្បទានទាន់ពេលវេលា នៅក្នុងសន្និសីទកំពូលលើកទី២០ ដើម្បីដំណើរការមូលនិធិនេះប្រកបដោយប្រសិទ្ធិភាព។
- រដ្ឋាភិបាលនានាបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីការងារREDD$^{+}$ ហើយបានឯកភាពលើគោលការណ៍ណែនាំ និងនីតិវិធីវាយតម្លៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់គោល វិធីសាស្រ្តសម្រាប់ការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់។
- បង្កើតមជ្ឈមណ្ឌលបច្ចេកវិទ្យាអាកាសធាតុ និងបណ្តាញការងារ (CTCN)។
- សន្និសីទកំពូលលើកទី២០ នឹងប្រារព្ធធ្វើនៅទីក្រុងលីម៉ានៃប្រទេសប៉េរូ និងលើកទី២១ នៅទីក្រុងប៉ារីសនៃប្រទេសបារាំង។

## ក្របខ័ណ្ឌជាតិពិនិត្យតាមដាន និងវាយតម្លៃ.........

តាមរយៈវគ្គពិភាក្សាស្របគ្នា។

ជំហានបន្ទាប់ គឺធ្វើការគិតគូរពីដំណើរការក្របខ័ណ្ឌ M&E ដែលរួមមាន i) ពិនិត្យស្ថានភាពនៃប្រព័ន្ធ M&E នៅកម្ពុជា ដើម្បីរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងឧបករណ៍នានាដែលមានស្រាប់ ii) បង្កើត និងរៀបចំសេចក្តីព្រាងអំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមការងារ M&E ប្រែប្រួលអាកាសធាតុ iii) រួមបញ្ចូលសូចនាករការប្រែប្រួលអាកាសធាតុទៅក្នុងសូចនាករនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ iv) ពង្រឹងការសម្របសម្រួលរវាង CCCA និងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) ដើម្បីបង្កើតក្របខ័ណ្ឌ M&E សម្រាប់ការប្រែប្រួលអាកាសធាតុ និង v) បន្តការសិក្សាអំពីប័ណ្ណពិន្ទុភាពងាយរងគ្រោះ និងសមត្ថភាពបន្សុំាដោយផ្អែកលើរបាយការណ៍ជាតិលើកទីពីរ ស្តីពីការប្រែប្រួលអាកាសធាតុ។



*វគ្គពិភាក្សាអំពីសូចនាករអន្តរវិស័យ និងសូចនាករតាមវិស័យនៃក្របខ័ណ្ឌ M&E*

### ព័ត៌មានបន្ថែម៖

## ទិន្នន័យស្តង់ដារគោលទី១ របស់កម្ពុជាសម្រាប់វិស័យកិនស្រូវ ត្រូវបានអនុម័ត

ក្រុមប្រឹក្សាប្រតិបត្តិនៃយន្តការអភិវឌ្ឍន៍ស្អាត (CDM) នៃ UNFCCC បានអនុម័ត**សំណើរបស់អាជ្ញាធរជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតរបស់កម្ពុជា ស្តីពីទិន្នន័យស្តង់ដារគោល "ការប្តូរបច្ចេកវិទ្យាក្នុងវិស័យកិនស្រូវនៅកម្ពុជា"** នៅក្នុងសម័យប្រជុំលើកទី ៧៦ របស់ខ្លួន ពីថ្ងៃទី ៤ ដល់ ៨ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅទីក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ។ នៅកម្រិតពិភពលោក នេះគឺជាទិន្នន័យស្តង់ដារគោលទី៤ ដែលបានអនុម័ត និងជាស្តង់ដារគោលទី១ សម្រាប់វិស័យកិនស្រូវ។

ទិន្ន័យស្តង់ដារគោល ត្រូវបានរៀបចំរួមគ្នាដោយក្រសួងបរិស្ថានកម្ពុជា និងវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក (IGES) នៃប្រទេសជប៉ុន និងបានដាក់ជូនក្រុមប្រឹក្សាប្រតិបត្តិនៃ CDM សម្រាប់អនុម័តនៅខែធ្នូ ឆ្នាំ២០១២។ ស្តង់ដារនេះត្រូវបានប្រើប្រាស់សម្រាប់វិស័យកិនស្រូវ តាមរយៈការតម្លើងបរិក្ខារថ្មី និង/ឬការបំពាក់បន្ថែមលើបរិក្ខារដែលមានស្រាប់ ដើម្បីបង្កើតថាមពលមេកានិក ឬអគ្គិសនីសម្រាប់ដំណើរការកិនស្រូវ។ បច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច និងមានលក្ខណៈសមស្រប ជាមួយការផ្លាស់ប្តូរប្រភពថាមពល រួមមាន៖ ម៉ាស៊ីន និងការបង្កើតឧស្ម័នដោយប្រើអង្កាម តួប៊ីនចំហាយដោយប្រើចំហេះអង្កាម និងម៉ាស៊ីនកម្តៅដោយប្រើចំហេះអង្កាម។ ទិន្នន័យស្តង់ដារគោលដែលបានអនុម័ត ត្រូវបានរៀបចំឡើងដោយផ្អែកលើការអង្កេតនៅថ្នាក់ជាតិទៅលើរោងម៉ាស៊ីនកិនស្រូវប្រមាណ ៩២ ទីតាំង នៅកម្ពុជា។



*ការប្រកាសទទួលស្គាល់ទិន្នន័យស្តង់ដារគោល នៅទីក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ*

ទិន្នន័យស្តង់ដារគោលមួយ (ឬ សេណារីយ៉ូគោល) សម្រាប់គម្រោង CDM មួយ គឺជាសេណារីយ៉ូដែលបង្ហាញដោយសមហេតុផលនូវការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីប្រភព ដែលបណ្តាលមកពីសកម្មភាពមនុស្ស ដែលអាចកើតឡើងក្នុងករណីអវត្តមានសំណើគម្រោង CDM។ គោលបំណងនៃការបង្កើតទិន្នស្តង់ដារគោល គឺដើម្បីកាត់បន្ថយពេលវេលា និងថ្លៃចំណាយដែលទាក់ទងនឹងការបង្កើតគម្រោង CDM ។

មកទល់បច្ចុប្បន្ន កម្ពុជាមានគម្រោង CDM ចំនួន ១០ ដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិនៃ UN CDM ។ គម្រោងទាំងនេះត្រូវបានប៉ាន់ស្មានថា នឹងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណ ២លានតោនសមមូល $CO_2$ ក្នុងមួយឆ្នាំៗ និងផលិតអគ្គិសនី និងកម្តៅ ដែលប្រើប្រាស់ជាប្រភពថាមពលកើតឡើងវិញ ដូចជា រ៉ាវីអគ្គិសនី សំណល់កម្តៅពីឧស្សាហកម្ម សំណល់កសិកម្ម និងសំណល់ពីការចិញ្ចឹមសត្វ។

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដោយមានការគាំទ្រពីនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថានជាលេខាធិការដ្ឋាន បាន និងកំពុងដឹកនាំសម្របសម្រួលការរៀបចំ និងការអនុវត្តគោលនយោបាយ ផែនការ និងវិធានការនានា ដែលចាំបាច់សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ (CCCA) គឺជាកម្មវិធីទូលំទូលាយបែបច្នៃប្រឌិតថ្មីមួយ សម្រាប់ឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ព្រឹត្តិបត្រព័ត៌មាននេះ ផលិតដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រោមជំនួយឧបត្ថម្ភពី CCCA។

CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, Danida, SWEDEN

ក្រសួងបរិស្ថាន អគារលេខ ៤៨ វុក្ខវិថីព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥-២៣) ២១៨ ៣៧០
អ៊ីម៉ែល៖ admin@camclimate.org.kh គេហទំព័រ៖ www.camclimate.org.kh